# ឯកឧត្តម ចម ប្រសិទ្ធ អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយវិស័យឯកជន
# ស្តីពីលទ្ធភាពចងសម្ព័ន្ធភាពជាមួយកងកំលាំងប្រដាប់អាវុធកម្ពុជា

យោងតាមការអំពាវនាវនិងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាជក្រកម្ពុជា ក្នុងឱកាសដែលសម្តេចអញ្ជើញចុះសួរសុខទុក្ខកងទ័ព ដែលកំពុងឈរ ជើងនៅព្រំដែនខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី០៩ ខែ កុម្ភៈ ឆ្នាំ២០១០ ស្តីពីលទ្ធភាពនៃការចងសម្ព័ន្ធភាព រវាងវិស័យឯកជន និងកងកំលាំងប្រដាប់អាវុធ ដើម្បីចូលរួមឧបត្ថម្ភគាំទ្រដល់ជីវភាពរស់នៅរបស់កងទ័ព និងកងនគរបាលជាតិ ដែលកំពុងបោះទីតាំងនៅតាមតំបន់ដាច់ស្រយាល នៅរសៀលថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១០ នៅ ទីស្តីការក្រសួងពាណិជ្ជកម្ម មានរៀបចំកិច្ចប្រជុំជាមួយវិស័យឯកជន មកពីបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ដែលធ្វើប្រតិបត្តិការនៅកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដើម្បីផ្សព្វផ្សាយសេចក្តីអំពាវនាវរបស់ សម្តេចតេជោនាយករដ្ឋមន្ត្រី ស្តីពីលទ្ធភាពនៃការចងសម្ព័ន្ធ ភាពរវាងវិស័យឯកជន និងកងកំលាំងប្រដាប់អាវុធ ដែលរូបឯកឧត្តមផ្ទាល់ ឯកឧត្តម **ស៊ុន ចាន់ថុល** ឯកឧត្តម **អ៊ុក រ៉ាប៊ុន** និងឯកឧត្តម **ប៉ែន ស៊ីម៉ន** ត្រូវបាន សម្តេចតេជោនាយករដ្ឋមន្ត្រី ប្រគល់ភារកិច្ច ក្នុងការធ្វើទំនាក់ទំនង ជាមួយបណ្តាក្រុមហ៊ុននានា នៅកម្ពុជា ។

មានប្រសាសន៍នាឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបញ្ជាក់ថាៈ ការអំពាវនាវរបស់ សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងលក្ខណៈដូចគ្នា និងបណ្តាស្ថាប័នរដ្ឋនានា ដែលធ្លាប់បានចូលរួមជួយឧបត្ថម្ភ និង ចងសម្ព័ន្ធភាពជាមួយបណ្តាអង្គភាពកងទ័ព។ ប៉ុន្តែ ពេលនេះជាការអំពាវនាវថ្មីមួយទៀត ដែលបន្ថែមវិស័យ ឯកជនឱ្យមានសម្ព័ន្ធភាពជាលក្ខណៈត្រីភាគី ជាមួយស្ថាប័នស៊ីវិលរបស់រដ្ឋ និងអង្គភាពកងទ័ព ក្នុងការធ្វើឱ្យមាន ការផ្លាស់ប្តូរដ៏ធំមួយ នៅក្នុងជីវភាពរស់នៅរបស់កងទ័ពនិងក្រុមគ្រួសាររបស់ពួកគេ ដែលរួមមានជាង៦០ អង្គភាព ទាំងកងទ័ព និងនគរបាល នៅតាមទីកន្លែងផ្សេងៗគ្នា ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបញ្ជាក់ថាៈការអំពាវនាវស្តីពីការជួយឧបត្ថម្ភនេះ មិនមែនសំរាប់ ពង្រឹងកងទ័ព ដើម្បីកម្ពុជាធ្វើសង្គ្រាមជាមួយបណ្តាប្រទេសជិតខាងនោះទេ តែគឺដើម្បីផ្តល់នូវលក្ខណៈចាំបាច់ ជាមូលដ្ឋាន ដល់កងកំលាំងប្រដាប់អាវុធរបស់យើង និងក្រុមគ្រួសាររបស់ពួកគេ ដែលកំពុងឈរជើងនៅតាម តំបន់គ្រុនចាញ់ដាច់ស្រយាល ហើយខ្វះខាតទីជំរក ខ្វះខាតប្រព័ន្ធទូរគមនាគមន៍ សាលារៀន មន្ទីរពេទ្យ និង ប្រព័ន្ធទឹកស្អាតជាដើម ។សូមឱ្យក្រុមហ៊ុនឯកជនចាត់ទុកថាៈការជួយជ្រោមជ្រែងរបស់លោក-លោកស្រី ចំពោះកងទ័ព និងកងនគរបាលជាតិ គឺជាការទទួលស្គាល់ដោយផ្ទាល់ ចំពោះការខិតខំប្រឹងប្រែងពួកគាត់ ក្នុងការថែរក្សា សន្តិភាព និង ស្ថិរភាពនៅកម្ពុជា និង ដើម្បីក្រុមហ៊ុនឯកជនមានលទ្ធភាពធ្វើជំនួញ និងវិនិយោគប្រកបដោយ ភាពសុខសាន្ត ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានបន្ថែមថាៈការជួយឧបត្ថម្ភនេះ គឺផ្អែកលើមូលដ្ឋានស្ម័គ្រចិត្ត ដោយគ្មានការ បង្ខិតបង្ខំ ហើយឯកឧត្តមសូមធ្វើការវាយតំលៃខ្ពស់ និងកោតសរសើរ នូវរាល់ការជួយឧបត្ថម្ភនានា ទោះជាសាច់ប្រាក់ក្តី រឺសំភារៈក្តី ។ ក្នុងនោះក្រុមហ៊ុនអាចអញ្ជើញចុះចែកដោយផ្ទាល់ដៃ ឬ ចុះចែកជាមួយ គណៈកម្មការ ទទួលជំនួយ ដែលនឹងត្រូវបង្កើតឡើងដោយរាជរដ្ឋាភិបាល ។

រាល់ការជួយឧបត្ថម្ភទាំងអស់ រាជរដ្ឋាភិបាល នឹងផ្តល់ជូនវិញ្ញាបនប័ត្របញ្ជាក់ ដោយផ្អែកលើកំរិតនៃការ ចូលរួមវិភាគទានរបស់អ្នកជួយឧបត្ថម្ភម្នាក់ៗ ។